ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សាលក្រមព្រហ្មទណ្ឌ
លេខ: ៥៥(គ)/៣៥៩
ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ: ១០៧៩
ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១
-សំណុំរឿងជំនុំជម្រះលេខ: ១៥១
ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជំនុំជម្រះជាសាធារណៈ សាលសវនាការលេខ ក១ អគារក នៃសាលាដំបូងខេត្តសៀមរាប នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ប្រាំបួន ព្រឹក ដែលមានសមាសភាពចូលរួមដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ឋានៈអនុប្រធានសាលាដំបូង ជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះលើ ៖ សំណុំរឿងព្រហ្មទណ្ឌលេខ: ១០៧៩ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០២១ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] ស៊ីណា ភេទប្រុស ថ្ងៃខែឆ្នាំកំណើត០៨.០៩.១៩៩៥ ជនជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តសៀមរាប មុខរបរជាងឈើ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៨ ប្រពន្ធឈ្មោះ[redacted]ប៊ុនធីញ មានកូន ២នាក់ ឪពុកឈ្មោះ[redacted]លឿប(ស) ម្តាយឈ្មោះ [redacted] សួម(រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ មាន (ធ្លាប់ជាប់ពន្ធនាគាររយៈពេល ៣ឆ្នាំ ករណីគ្រឿងញៀន) ។ (ក្នុងឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៦៤១ឃខ/ឋ ចុះថ្ងៃទី២២ ខែវិច្ឆិកាឆ្នាំ២០២១។

២.ឈ្មោះ [redacted] ឧត្តម ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០៣.០៥.២០០៣ ជនជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តសៀមរាប មុខរបរគ្មាន កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី ១០ នៅលីវ ឪពុកឈ្មោះ [redacted] ណាន (រ) ម្តាយឈ្មោះ [redacted] ស៊ី (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។(ក្នុងឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៦៤០ ឃខ/ឋ ចុះថ្ងៃទី២២ ខែវិច្ឆិកាឆ្នាំ២០២១។



Scanned with CamScanner

៣. ឈ្មោះ [redacted]ទី ភេទប្រុស ឆ្នាំកំណើត១៩៩៨ ជនជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តសៀមរាប មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៨ ប្រពន្ធឈ្មោះ [redacted] ចេក មានកូន ២នាក់ ឪពុកឈ្មោះ [redacted]គឿម(រ) ម្តាយឈ្មោះ [redacted]ឡុប (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ (ក្នុងឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៦៣៩ យខ/ឋ ចុះថ្ងៃទី២២ ខែវិច្ឆិកាឆ្នាំ២០២១។

ជាប់ចោទពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្វៀន និងភូមិគោកតាចាន់ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ទី និងឈ្មោះ [redacted] ឧត្តម និងមានលោកស្រី [redacted] ស្រីម៉ីរ៉ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]ឧត្តម ។

**<u>អង្គហេតុកើតឡើងមានដូចតទៅ:</u>**

កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ០០ នាទី កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀនបានចុះធ្វើការបង្ក្រាបមុខសញ្ញាជួញដូរគ្រឿងញៀនខុសច្បាប់ចំនួន ០២នាក់មានឈ្មោះ [redacted] ទី និងឈ្មោះ [redacted] ឧត្តម នៅចំណុចលំនៅឋានក្បែរគ្នា ស្ថិតនៅភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ដកហូតបានថ្នាំញៀនចំនួន ០៥កញ្ចប់ ទម្ងន់ ០,៣៨ក្រាម នៅក្នុងហោប៉ៅរបស់ជនជាប់ចោទឈ្មោះ [redacted]ទី ព្រមទាំងដកហូតសម្ភារៈប្រើប្រាស់ថ្នាំញៀនមួយចំនួន។ ក្រោយពីធ្វើការសាកសួរឈ្មោះ [redacted] ទី បានឆ្លើយសារភាពថា ថ្នាំញៀនទាំងនេះទិញពីឈ្មោះ [redacted] ស៊ីណា រស់នៅភូមិគោកតាចាន់ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ទុកសម្រាប់ប្រើប្រាស់ ហើយសមត្ថកិច្ចបានបន្តធ្វើការឃាត់ខ្លួនឈ្មោះ [redacted] ស៊ីណា ដកហូតថ្នាំញៀនចំនួន ០៧កញ្ចប់ ទម្ងន់ ០,៨០ក្រាម ដែលលាក់នៅក្នុងហោប៉ៅទុកសម្រាប់ប្រើប្រាស់។ ក្រោយពីធ្វើការសាកសួរ ឈ្មោះ [redacted]ស៊ីណា បានសារភាពថា ថ្នាំញៀនទិញពីមនុស្សម្នាក់មិនស្គាល់ឈ្មោះ ប្រើប្រាស់ទូរស័ព្ទលេខ ០១៥ ៩៨៤ ៣៣៤ ដោយវេរប្រាក់ឲ្យគេមុន ហើយថ្នាំញៀនគេយកមកប្លង់ចោលនៅផ្លូវទៅអង្គរ ។

បានឃើញៈ របាយការណ៍សំយោគ លេខ ៧២០/២១ ប្រ.គ្រ.ញ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។

បានឃើញៈ ដីកាសន្និដ្ឋានស្ថាពរលេខៈ ១០៨ អយយ/២០២២ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញៈ ដីកាដំណោះស្រាយ លេខៈ ៩២២ពស.ព្រស/ឋ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

បានឃើញៈ ដីកាចាត់តាំងចៅក្រមជំនុំជម្រះ លេខ ១៧២ ពស.ព្រជ(ក) ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។



Scanned with CamScanner

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] ទី បានឆ្លើយថា ៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ សមត្ថកិច្ចឃាត់ខ្លួន នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ៩ព្រឹក នៅផ្ទះរបស់ខ្លួន(ផ្សារភូមិភាគ) ស្ថិតនៅភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ខណៈពេលដែលខ្លួនកំពុងដេក ។ ពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតថ្នាំញៀនចំនួន ៥កញ្ចប់តូច នៅក្នុងហោប៉ៅខោ និងទូរស័ព្ទដៃម៉ាក vivo មួយគ្រឿង ។ ថ្នាំញៀននេះ ខ្លួនទិញពីមនុស្សប្រុសមិនស្គាល់ឈ្មោះ មិនចេះលេខទូរស័ព្ទ ។ ថ្នាំញៀនចំនួន ៥កញ្ចប់ ទិញក្នុងតម្លៃ ៦០០០០(ប្រាំមួយម៉ឺន)រៀល ទិញសម្រាប់ប្រើប្រាស់ខ្លួនឯង ខ្លួនធ្លាប់ទិញថ្នាំញៀនចំនួន ៣ដង ដោយអ្នកលក់យកមកប្លង់ទុកចោលនៅក្បែរភោជនីយដ្ឋានប្រាសាទនាងពៅ ។ ខ្លួនប្រើប្រាស់ថ្នាំញៀនចុងក្រោយ នៅល្ងាចថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ៨យប់ជាមួយឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ស៊ីណា នៅផ្ទះរបស់ខ្លួនក្នុងផ្សារភូមិភាគ ។ មូលហេតុដែលខ្លួនទិញថ្នាំញៀនទុកសម្រាប់ប្រើប្រាស់ដោយសារ ខ្លួនអត់ងងុយពេលយប់ក្នុងការដើរឆ្លេះខ្យង ។

- ជនជាប់ចោទឈ្មោះ [redacted]ឧត្តម បានឆ្លើយថា ៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២១ នៅផ្ទះរបស់ខ្លួន ខណៈពេលដែលខ្លួនកំពុងដេក ។ ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងធ្វើតេស្តទឹកនោម ឃើញមានសារធាតុញៀននៅក្នុងខ្លួន ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] ស៊ីណា ទេរីឯឈ្មោះ [redacted] ទី ខ្លួនស្គាល់ដោយសារមានផ្ទះនៅក្បែរគ្នា តែមិនដែលមានទំនាក់ទំនងនឹងគ្នាទេ ។ ខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ ឌី ចំនួន ២ដង តម្លៃចាប់ពី ៥០០០(ប្រាំពាន់)រៀល ទៅ ១០០០០(មួយម៉ឺន)រៀល យកមកប្រើប្រាស់តែម្នាក់ឯងនៅផ្ទះ។ ពេលទិញថ្នាំញៀន ខ្លួនបានវេប្រាក់ជាមុនឲ្យទៅឈ្មោះ ឌី ។ ឈ្មោះ ឌី ខ្លួនស្គាល់តាមរយៈមិត្តភក្តិ ។

- ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា បានឆ្លើយថា ៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ សមត្ថកិច្ចឃាត់ខ្លួននៅផ្ទះខ្លួន ខណៈពេលដែលខ្លួនកំពុងដេកជាមួយប្រពន្ធ ហើយបានដកហូតថ្នាំញៀនចំនួន ៧កញ្ចប់ និងឧបករណ៍ប្រើប្រាស់មួយចំនួន ។ ថ្នាំញៀននេះ ខ្លួនទិញពីមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ កាន់ទូរស័ព្ទលេខ ០១៥ ៩៤៤ ៣៣៤ ដែលខ្លួនទិញកាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២១ ក្នុងតម្លៃ ១៥០០០០(ដប់ប្រាំម៉ឺន)រៀល ដោយអ្នកលក់យកទៅប្លង់ចោលនៅផ្លូវអង្គវត្ត ហើយខ្លួនវេប្រាក់ឲ្យអ្នកលក់ថ្នាំញៀនមុនពេលដែលខ្លួនទៅយកថ្នាំញៀន។ ខ្លួនបានទិញថ្នាំញៀនចំនួន ៣ដង គឺនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ទិញចំនួន ៥កញ្ចប់ តម្លៃ ១០០០០០(ដប់ម៉ឺន)រៀល ,នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ទិញចំនួន ៥កញ្ចប់ តម្លៃ ១០០០០០(ដប់ម៉ឺន)រៀល និងលក់ចុងក្រោយនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២១ ។ ខ្លួនទិញទុកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ និងការពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទទាំងបីនាក់មានធាតុផ្សំគ្រប់គ្រាន់ពីបទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ។ តំណាងអយ្យការស្នើសុំប្តូរបទចោទប្រកាន់លើជនជាប់ចោទទាំងបីនាក់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ទៅបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ជំនួសវិញ និងប្តឹងសុំទៅក្រុមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងបីនាក់ទៅតាមច្បាប់ ។



Scanned with CamScanner

## សេចក្ដីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យ
## ជនជាប់ចោទឈ្មោះ [redacted] ទី និងឈ្មោះ នី ឧត្តម

តាមការសន្និដ្ឋានរបស់តំណាងអយ្យការបានប្ដូរបទចោទពីបទជួញដូរមកបទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនលើជនជាប់ចោទទាំងបីនាក់ ,កូនក្ដីខ្លួនទិញមកដើម្បីទុកប្រើប្រាស់ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ហេតុនេះសូមចៅក្រមជំនុំជម្រះប្ដូរបទចោទកូនក្ដីខ្លួនទៅបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដោយអនុគ្រោះ ។

## សេចក្ដីសន្និដ្ឋានរបស់លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យ
## ជនជាប់ចោទឈ្មោះ [redacted] ឧត្តម

តាមសវនាការនេះ ឃើញថា កូនក្ដីខ្លួនឈ្មោះ [redacted] ឧត្តម មិនបានលក់ថ្នាំញៀនទេ គាត់ទិញមកដើម្បីទុកប្រើប្រាស់តែប៉ុណ្ណោះ ហេតុនេះ សូមចៅក្រមជំនុំជម្រះប្ដូរបទចោទពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ទៅជាបទ ប្រើប្រាស់ដោយខុសច្បាប់នូវសាធាតុញៀន ជំនួសវិញដោយអនុគ្រោះ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ទី បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សូមតុលាការមេត្តាជួយសម្រាលទោសដល់ខ្លួនដោយអនុគ្រោះ ។

-ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សូមតុលាការមេត្តាជួយសម្រាលទោសដល់ខ្លួនដោយអនុគ្រោះ ។

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សូមតុលាការមេត្តាជួយសម្រាលទោសដល់ខ្លួនដោយអនុគ្រោះ ។

ក្រោយពីបាន ស្ដាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបាន ស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបាន ស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបាន ស្ដាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបាន ពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់

## <u>សំអាងហេតុ</u>

១- តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១០៧៩ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ តាមដីកាដំណោះស្រាយ លេខ: ៩២២ ពស.ព្រស/ឋ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ភេទប្រុស ឆ្នាំកំណើត ១៩៩៥ ជនជាតិខ្មែរ ,ឈ្មោះ [redacted] ឧត្តម ភេទប្រុស ឆ្នាំកំណើត២០០២ ជនជាតិខ្មែរ និងឈ្មោះ [redacted] ទី ភេទប្រុស ឆ្នាំកំណើត ១៩៩៨ ជនជាតិខ្មែរ មកជំនុំជម្រះពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វៀន និងភូមិគោកតាចាន់ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២- តាមរបាយការណ៍សំយោគលេខ ៧២០/២១ប្រ.គ្រ.៣ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានសន្និដ្ឋានបញ្ជាក់ថា សកម្មភាពនៃអំពើខាងលើជាបទល្មើស រក្សាទុក ,ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលប្រព្រឹត្តដោយជនសង្ស័យឈ្មោះ [redacted] ទី និងឈ្មោះ [redacted] ស៊ីណា និងបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តដោយជនសង្ស័យឈ្មោះ [redacted] ឧត្តម ។

៣- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ទី ,ឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ស៊ីណា បានឆ្លើយនាពេលសវនាការ ជនជាប់ចោទបានឆ្លើយសារភាព ។ តាមចម្លើយជនជាប់ចោទទាំងបីនាក់ និងវត្ថុតាងដែលបានដកហូតជាក់ស្តែងពីជនជាប់ចោទ ព្រមទាំងឯកសារនានា ដែលមាននៅក្នុងសំណុំរឿង ឃើញថា សកម្មភាពរបស់ជនជាប់ចោទមានធាតុផ្សំបទល្មើសគ្រប់គ្រាន់បទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ពុំមានធាតុផ្សំបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀននោះទេ ។ គប្បីតុលាការសម្រេចកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ទី ,ឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ស៊ីណា ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនវិញ ។

៤- តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការថា ជនជាប់ចោទទាំងបីនាក់មានធាតុផ្សំគ្រប់គ្រាន់ពីបទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ។ តំណាងអយ្យការស្នើសុំប្តូរបទចោទប្រកាន់លើជនជាប់ចោទទាំងបីនាក់ពីបទ ជួញដូរដោយខុសច្បាប់នូវសាធាតុញៀន ទៅបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ជំនួសវិញ និងប្តឹងសុំចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងបីនាក់ទៅតាមច្បាប់ ។ គប្បីតុលាការលើកយកការសន្និដ្ឋានរបស់តំណាងអយ្យការមកពិចារណាក្នុងការសម្រេចសេចក្តី ។

៥- តាមកំណត់ហេតុឆែកឆេរ លេខ ៧២២/០២១ ក.ណ.ហ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានបញ្ជាក់ថា បានធ្វើការឆែកឆេរ និងធ្វើការចាប់យកសម្ភារៈវត្ថុតាងមានដូចជា ដបកែវ ដែលគំរបចោះរន្ធពីរ ច្នៃសម្រាប់ប្រើប្រាស់គ្រឿងញៀន,ដែកកេះពណ៌លឿង ចំនួនមួយ ច្នៃសម្រាប់ជក់គ្រឿងញៀន,បំពង់បឺតចំនួនប្រាំពីរ ច្នៃសម្រាប់ជក់គ្រឿងញៀន ,ឧបករណ៍វេចខ្ចប់គ្រឿងញៀនមួយចំនួន ដែលវត្ថុតាងខាងលើដាក់នៅក្នុងកាបូបពណ៌ខ្មៅរ៉ូត ទុកលើក្បាលគ្រែនៅលំនៅឋានរបស់ឈ្មោះ [redacted] ស៊ីណា ស្ថិតនៅភូមិគោកតាចាន់ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ហើយនិងបានឆែកឆេរចាប់យកវត្ថុតាងមានដូចជា ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន ,ថង់កឹបមាត់ពណ៌សដែលសេសសល់កំទេចគ្រឿងញៀន ចំនួន បីថង់ រកឃើញនៅលំនៅឋានរបស់ឈ្មោះ [redacted] ឧត្តម ស្ថិតនៅភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ។

៦-តាមកំណត់ហេតុទទួល ស្គាល់សម្ភារៈ និងវត្ថុតាង លេខ ៧២៣/០២១ក.ណ.ហ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានបញ្ជាក់ថា វត្ថុតាងដែលដកហូតមាន ម្សៅក្រាមពណ៌សថ្លាចំនួន ៧កញ្ចប់ គឺជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ពិតជាបានដកហូតពីឈ្មោះ [redacted] ស៊ីណា និងវត្ថុតាងបានដកហូតមាន ម្សៅក្រាមពណ៌សថ្លាចំនួន ៥កញ្ចប់គឺជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ពិតជាបានដកហូតពីឈ្មោះ [redacted] ទី ពិតប្រាកដមែន ។



Scanned with CamScanner

៧-តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន លេខ: ៧២៥/០២១ក.ណ.ហ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានបញ្ជាក់ថា បានធ្វើតេស្តទឹកនោមលើឈ្មោះ [redacted] ទី ,ឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ស៊ីណា ជាលទ្ធផល គឺវិជ្ជមាន មានសារធាតុញៀននៅក្នុងខ្លួនទាំងបីនាក់ (មានតម្រុយមេតំហ្វេតាមីន) ។

៨-តាមកំណត់ហេតុស្តីពីការបើក បិទ និងដកសំណាកវត្ថុចាប់យករបស់ជនត្រូវចោទ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាបបានបញ្ជាក់ថា ក្រោយពីបើកសំណាកថ្នាំញៀនរួច ឃើញថា ថ្នាំញៀនរបស់ជនជាប់ចោទឈ្មោះ [redacted] ទី ចំនួន ១កញ្ចប់មានទម្ងន់សុទ្ធ ០,៣៨ (សូន្យក្បៀសសាមសិបប្រាំបី)ក្រាម និងថ្នាំញៀនរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ចំនួន ១កញ្ចប់ ទម្ងន់សុទ្ធ ០,៨០(សូន្យក្បៀសប៉ែតសិប)ក្រាម ។

៩-តាមលទ្ធផលកោសលវិច័យគ្រឿងញៀន លេខ ៣៤៣៧៣/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិកាដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថា សំណាកដែលដកហូតពីជនជាប់ចោទ គឺជាគ្រឿងញៀន មានវត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៧៥,៦៧%(ចិតសិបប្រាំក្បៀសហុកសិបប្រាំពីរ)ភាគរយ នៃទម្ងន់សរុប ។ ដូចនេះ បរិមាណសុទ្ធ នៃថ្នាំញៀនមាន (០,៨០ X៧៥,៦៧)/១០០ = ០,៦០(សូន្យក្បៀសហុកសិប)ក្រាម ដែលបរិមាណសុទ្ធនេះមានចំនួនតិចជាង ១៥ក្រាម ។

១០-តាមលទ្ធផលកោសលវិច័យគ្រឿងញៀន លេខ ៣៤៣៧៤/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិកាដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថា សំណាកដែលដកហូតពីជនជាប់ចោទ គឺជាគ្រឿងញៀន មានវត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៧៥,៦៧%(ចិតសិបប្រាំក្បៀសហុកសិបប្រាំពីរ)ភាគរយ នៃទម្ងន់សរុប ។ ដូចនេះ បរិមាណសុទ្ធ នៃថ្នាំញៀនមាន (០,៣៨ X៧៥,៦៧)/១០០ = ០,២៨(សូន្យក្បៀសម្ភៃប្រាំបី)ក្រាម ដែលបរិមាណសុទ្ធនេះមានចំនួនតិចជាង ១៥ក្រាម ។

១១- សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ទី ,ឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ស៊ីណា ត្រូវបានច្បាប់កំណត់ថា ជាបទល្មើស រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ហើយញត្តិឲ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំទៅ ៥(ប្រាំ) ឆ្នាំ និង អាចពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ។

១២-អំពើរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយល្អក្នុងសង្គមដែលច្បាប់ហាមឃាត់ ជាពិសេសបានបំពានទៅនឹងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៣- ជនជាប់ចោទជា នីតិជន ដែលមានសមត្ថភាពស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។



Scanned with CamScanner

១៤- មានបន្ទុក និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ភេទប្រុស ឆ្នាំកំណើត ១៩៩៥ ជនជាតិខ្មែរ ,ឈ្មោះ [redacted] ឧត្តម ភេទប្រុស ឆ្នាំកំណើត ២០០៣ ជនជាតិខ្មែរ និងឈ្មោះ [redacted] ទី ភេទប្រុស ឆ្នាំកំណើត១៩៩៨ ជនជាតិខ្មែរ ពីបទៈ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វៀន និងភូមិគោកតាចាន់ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៥- វត្ថុចាប់យកដូចមានក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខៈ ២៧៥/២១ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប មានដូចជា ៖

ក.ស្រោមសំបុត្រពណ៌ខ្លីមខ្ទុះបិទជិត មានស្នាមមេដៃរបស់ឈ្មោះ [redacted] ទី និងឈ្មោះ [redacted] ស៊ីណា និងហត្ថលេខាលោក [redacted] ណាម ចំនួន ០១ ។

ខ.ទូរស័ព្ទដៃម៉ាក VOVI(AL SUPER CAMERA F2.2-2.4 ASPH) មិនស្គាល់ Model ពណ៌ខៀវ (បែកស្គ្រីនមុខ) ចំនួន ០១គ្រឿង ។

គ.ទូរស័ព្ទដៃម៉ាក NOKIA Model TA-1114 ពណ៌ខ្មៅ ចំនួន ០១គ្រឿង ។

គឺជាវត្ថុតាង នៃបទល្មើស ដូចនេះ តុលាការសម្រេចរឹបអូសតាមមាត្រា៦២ ,មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ហេតុដូច្នេះ សម្រេច

**១.**កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] **ស៊ីណា** ភេទប្រុស ឆ្នាំកំណើត១៩៩៥ ជនជាតិខ្មែរ ,ឈ្មោះ [redacted] **ឧត្តម** ភេទប្រុស ឆ្នាំកំណើត ២០០៣ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ទី** ភេទប្រុស ឆ្នាំកំណើត ១៩៩៨ ជនជាតិខ្មែរ ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្វៀន និងភូមិគោកតាចាន់ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្វៀន និងភូមិគោកតាចាន់ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី១ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

**២.ផ្តន្ទាទោសៈ**

ក.ឈ្មោះ [redacted] **ស៊ីណា** ភេទប្រុស ឆ្នាំកំណើត១៩៩៥ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន)រៀល ។**

ខ.ឈ្មោះ [redacted] **ឧត្តម** ភេទប្រុស ឆ្នាំកំណើត២០០៣ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **២(ពីរ)ឆ្នាំ តែទោសនេះត្រូវអនុវត្តរយៈពេល ១(មួយ) ៦(ប្រាំមួយ)ខែ ទោសដែលនៅសល់ព្យួរទោស ។**



Scanned with CamScanner

គ. ឈ្មោះ [redacted] ទី ភេទប្រុស ឆ្នាំកំណើត១៩៩៨ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ តែទោសនេះត្រូវអនុវត្តរយៈពេល ១(មួយ) ៦(ប្រាំមួយ)ខែ ទោសដែលនៅសល់ព្យួរធម្មតា ។

ពីបទ: **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្វៀន និងភូមិគោកតាចាន់ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី១ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២/- វត្ថុចាប់យកដូចមានក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខៈ ២៧៥/២១ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប មានដូចជា ៖

ក.ស្រោមសំបុត្រពណ៌ខ្លីមខ្ទុរបិទជិត មានស្នាមមេដៃរបស់ឈ្មោះ [redacted] ទី និងឈ្មោះ [redacted] ស៊ីណា និងហត្ថលេខាលោក [redacted] ណម ចំនួន ០១ ។

ខ.ទូរស័ព្ទដៃម៉ាក VOVI(AL SUPER CAMERA F2.2-2.4 ASPH) មិនស្គាល់ Model ពណ៌ខៀវ (បែកស្រ្គីនមុខ) ចំនួន ០១គ្រឿង ។

គ.ទូរស័ព្ទដៃម៉ាក NOKIA Model TA-1114 ពណ៌ខ្មៅ ចំនួន ០១គ្រឿង ។

**សម្រេចរឹបអូស** តាមមាត្រា ៦២ ,មាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ទី ,ឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ស៊ីណា។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
សៀមរាប , ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner